# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូសមាគមអាជីវកម្ម ទឹកស្អាតក្រៅប្រទេសនៃទីក្រុង **Kitakyushu** ជប៉ុន




នៅថ្ងៃទីរសៀល ២២ ខែ មករា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូ សមាគមអាជីវកម្មទឹកស្អាតក្រៅប្រទេសនៃទីក្រុង **Kitakyushu** ជប៉ុន ហៅកាត់ថា: **KOWBA** ដឹកនាំដោយលោក **INUOE Yuji** ជាប្រធានសមាគម ដើម្បពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **INUOE Yuji** ប្រធានសមាគមអាជីវកម្មទឹកស្អាតក្រៅប្រទេសនៃទីក្រុង Kitakyushu ជប៉ុន បានជម្រាបជូនពិគោលបំណងនៃជំនួបពិភាក្សាមាន ០២ចំណុចៈ **ទី១** –ធ្វើសេចក្តីរាយការណ៍ពីរបាយការណ៍អង្កេតសង្ខេបរបស់សមាគម KOWBA មានរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី០២ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ទៅលើក្រុមហ៊ុនឯកជនមួយកន្លែងឈ្មោះ ព្រៃគុបខនស្ត្រាក់សិន ដែលមានទីតាំងស្ថិតនៅក្នុងភូមិផ្សារលិច ឃុំព្រែកឡៅ ស្រុកពញាឮ ខេត្តកណ្តាល និងតំបន់សេវាគ្របដណ្តប់ចំនួន៩០ភូមិ ០៣សង្កាត់ និង០៦ឃុំ ស្តីពីការសន្ទស្សន៍ថៃថាមពល និងវិធានការស្តីពីការគ្រប់គ្រងបណ្តាញចែកចាយទឹកស្អាតសមស្រប លទ្ធផលឃើញថាៈក្រុមហ៊ុននៅមានការខ្វះខាតផ្នែកការគ្រប់គ្រង និងបំពាក់បរិក្ខាបច្ចេកទេសដែលធ្វើឱ្យការចំណាយថ្លៃដើមឡើងខ្ពស់ ។ **ទី២**–បានជម្រាបជូនពីគម្រោងរៀបចំសិក្ខាសាលាមួយនៅសណ្ឋាគារ **Inter-Continental** គឺសិក្ខាសាលា ស្តីអំពីអាជីវកម្មទឹកស្អាតរវាងកម្ពុជា–ជប៉ុន និងកម្មវិធីផ្គូរផ្គងអាជីវកម្ម ។ សិក្ខាសាលានេះនឹងមានការជួបជុំគ្នាពីអ្នកជំនាញទឹកស្អាតមកពីក្រុមហ៊ុនជប៉ុន ជាមួយផ្នែកពាក់ព័ន្ធវិស័យទឹកស្អាតនៅកម្ពុជា ដើម្បីដកស្រង់បទពិសោធន៍ និងបទបង្ហាញពីបច្ចេកទេសថ្មីៗលើវិស័យគ្រប់គ្រង និងផលិតទឹកស្អាត ។ ក្នុងនោះក៏មានក្រុមហ៊ុន ជប៉ុនចំនួន១២ ចូលរួមតាំងពិព័រណ៍ផលិតផលវិស័យទឹកស្អាតរបស់ខ្លួនផងដែរ ។



មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះលទ្ធផលអង្កេតរបស់សមាគម COWBA ដែលប្រើរយៈពេលត្រឹមតែ១០ថ្ងៃប៉ុណ្ណោះ ទទួលបានលទ្ធផលគួរឱ្យទុកចិត្តបាន ព្រោះលទ្ធផលទាំងនេះបានបង្ហាញនូវភាពខ្វះចន្លោះជាច្រើនរបស់ក្រុមហ៊ុនអាជីវកម្មទឹកស្អាតឯកជន ដូចជា : ខ្ជះខ្ជាយការប្រើប្រាស់ថាមពល–ការប្រើប្រាស់ម៉ាស៊ីនបូមមិនសមស្រប–មិនមានឧបករណ៍វាស់ស្ទង់បរិមាណទឹកផលិតនិងផ្គត់ផ្គង់–ខ្វះឧបករណ៍វាស់ស្ទង់ការពារទឹកលេចធ្លាយ–ខ្វះវិធានការកែលំអរបណ្តាញចែកចាយ–ប្រសិទ្ធិភាពចំណាយ និងមិនមានផែនទីមេសម្រាប់តាមដានមើលបំពង់ទឹកកប់ក្រោមដីជាដើម ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា: របាយការណ៍អង្កេតនៅក្រុមហ៊ុនឯកជនមួយនេះ ជាមូលដ្ឋានដើម្បីធ្វើការវាយតម្លៃ និងកែលម្អរដល់មូលដ្ឋានផលិតទឹកស្អាតឯកជនដ៏ទៃទៀតទូទាំងប្រទេស ពីព្រោះក្រុមហ៊ុនឯកជនទាំងនោះមានបញ្ហាមិនខុសគ្នាទេ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យសមាគម COWBA ជប៉ុនពិនិត្យលទ្ធភាពតម្លើងគំរូប្លង់រោងចក្រផលិតទឹកស្អាតមួយឈុតតាមខ្នាតធំ តូចតែម្តង ដើម្បីឱ្យវិស័យឯកជនជាវយកទៅផលិតតាមបច្ចេកទេសតែមួយ ។ ការងារនេះយើងងាយស្រួលក្នុងការគ្រប់គ្រងគុណភាពទឹក និងកំណត់ថ្លៃលក់ទឹកជូនប្រជាពលរដ្ឋអ្នកប្រើប្រាស់ឱ្យបានសមស្រប។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានស្នើឱ្យមានការជួយបណ្តុះបណ្តាលជំនាញទឹកស្អាតដល់មន្ត្រីក្រសួង និងផ្នែកឯកជន ព្រមទាំងបង្កើតក្រុមហ៊ុនជំនាញទឹកស្អាតនៅកម្ពុជាផងដែរ ។ ដោយឡែក ទាក់ទង និងការរៀបចំសិក្ខាសាលានៅពេលខាងមុខ ឯកឧត្តម ឯកភាព ហើយក៏នឹងញើញចូលរួមជាអធិបតីបិទផងដែរ ។

